ប៉ារីសថ្ងៃទី ៣១ ខែ មិនា ឆ្នាំ២០១៣

# តុលាការអន្តរជាតិឬ ICC (ត)

បន្ទាប់ពីមានការចុះផ្សាយអត្ថបទទាក់ទងនឹង« **តុលាការអន្តរជាតិ**» ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៣ និងកិច្ចសម្ភាសដ៏ខ្លីមួយជាមួយវិទ្យុខ្មែរពិភពលោក មានអ្នកស្តាប់មួយចំនួនដែលមាននិន្នាការជ្រុលនិយមនិងជំនឿផ្តាប់មុខមានការខឹងសម្បារនិងអ្នកខ្លះភន័ច្រឡំ ។ អវិជ្ជានិងជំនឿផ្តាប់មុខជាគ្រោះថ្នាក់ខ្លាំងណាស់ដល់សង្គមជាតិ ។ ដោយសារតែសង្គមខ្មែរសម្បូរមនុស្សប្រភេទនេះ ទើបប្រទេសខ្មែរធ្លាក់ក្នុងមហន្តរាយម្តងហើយម្តងទៀតគ្មានទីបញ្ចប់ ។ ខ្មែរខ្លៅអវិជ្ជា អគតិ ត្រូវសត្រូវបោកប្រាស់ប្រើអោយបំផ្លាញជាតិ អោយកាប់សម្លាប់ជនជាតិឯង បន្ទាប់មកត្រូវគេសម្លាប់ចោលដូចសត្វជាតុហើយមិនរវល់រកហេតុផលខុសត្រូវអ្វីទាំងអស់ ។ ដោយឃើញគ្រោះថ្នាក់នៅចំពោះមុខ ហើយដោយយើងជាមនុស្សឯករាជ្យ មានការខ្វល់ខ្វាយពីបញ្ហាសង្គមជាតិ ចង់ឃើញសង្គមជាតិរុងរឿងថ្លៃថ្នូរ វាចាកពីគ្រោះមហន្តរាយ ទើបខ្ញុំនិងមិត្តភក្តិព្យាយាមចំណាយពេលវេលាកម្លាំងកាយចិត្តនិងថវិការផ្ទាល់ខ្លួនស្រាវជ្រាវនិងផ្សព្វផ្សាយឯកសារទាំងឡាយដែលយើងគិតថា មានសារៈសំខាន់សម្រាប់ជនរួមជាតិយកទៅត្រិះរិះពិចារណាស្វែងរកការពិត, ឬបើអាច, ស្វែងរកដំណោះស្រាយដ៏ពិតប្រាកដមួយដោយឈរលើតថភាព, សច្ចៈភាពនិងភាពប្រាកដនិយម ។

ខ្ញុំសូមជម្រាបថា ខ្ញុំមិនមែនជាអ្នកឯកទេសខាងតុលាការអន្តរជាតិទេ ហើយអត្ថបទនិងកិច្ចសម្ភាសដ៏ខ្លីដែលខ្ញុំបានបានផ្តល់មិនអាចអោយខ្ញុំយកចំណុចលំអិតតូចៗមកបកស្រាយបានទេ ។ ខ្ញុំគ្រាន់តែដកស្រង់យកចំណុចសំខាន់ៗធំៗតែប៉ុណ្ណោះដើម្បីជាគោលសម្រាប់ការស្វែងយល់ ខ្ញុំពុំបានឈានដល់ការបកស្រាយលំអិតចំណុចនិមួយៗទេ ដូចជាក្នុងកិច្ចសម្ភាស ខ្ញុំបានចុចជាសំខាន់ពីករណីជាក់ស្តែងពិតប្រាកដនិងប្រាកដនិយមដែលអាចឈានដល់ការបើកនីតិក្រមនិងកោះហៅជនជាប់ចោទមកកាត់ទោសដូចករណីមេដឹកនាំនៅទ្វិបអាហ្វ្រិក ។ល។ បើនិយាយពីការដាក់ពាក្យបណ្តឹងវិញ ជាការពិត តុលាការអន្តរជាតិអាចទទូលយកពាក្របណ្តឹងពីបុគ្គល ពីក្រុម, ពីគណៈបក្សនយោបាយឬពីសហគមអចិន្ត្រៃអន្តរជាតិចំពោះបទឧក្រិដ្ឋកម្មធ្ងន់ៗនិងដែលស្ថិតក្នុងគ្រងខ័ណ្ឌលក្ខន្តិកៈរ៉ូម, មាន : ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មឈ្លានពាន ហើយដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តិក្រោយថ្ងៃដែលគេបានបញ្ចូលលក្ខន្តិកៈរ៉ូមជាធរមាន(ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២) តែដើម្បីឈានដល់ការបើកនីតិក្រម តុលាការអន្តរជាតិទាមទារការសហការជាមួយរដ្ឋាភិបាលនៃប្រទេសនោះ ព្រោះតុលាការអន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ណាស់ថា តុលាការអន្តរជាតិមិនអាចរំលងតុលាការជាតិបានទេ តុលាការអន្តរជាតិគ្រាន់តែជាតុលាការបន្ថែមលើតុលាការជាតិតែប៉ុណ្ណោះ ។ សូមបញ្ជាក់ថា និយមនយ័នៃឧក្រិដ្ឋកម្មទាំងឡាយក្នុងលក្ខន្តិកៈរ៉ូម គេតែងយោងតាមអ្វីដែលបានកើតឡើងក្នុងសង្គ្រាមលោកលើកទីពីរ ។ល។ ហើយនិតិវិធីរបស់តុលាការអន្តរជាតិមានភាពតឹងតែងខ្លាំងណាស់ អាចធ្វើបានលើតែករណីជាក់ស្តែងមានភស្តុតាងគ្រប់គ្រាន់ ។ ត្រូវដឹងថា គឺរដ្ឋាភិបាលលោកហ៊ុនសែនដែលបានបានចុះហត្ថលេខានិងអោយសច្ចានុម័តិលើលក្ខន្តិកៈរ៉ូម ពួកនេះដឹងច្បាស់លាស់ណាស់ចំពោះអ្វីដែលគេធ្វើ ព្រោះហ៊ុនសែនមានពួកបណ្ឌិតច្បាប់ជាតិនិងអន្តរជាតិនៅជុំវិញខ្លួនដើម្បីណែនាំនិងបំពេញការងារអោយ ។ អ្នកដែលខ្លៅហើយមិនដឹងគឺពួកមនុស្សទាំងឡាយដែលជឿលើការឃោសនាអកុសលរបស់ជនពាលបោកប្រាស់ដែលបានដើរឃោសនាបំពុលខ្មែរល្ងង់ខ្លៅថា គេអាចប្រើតុលាការអន្តរជាតិដើម្បីប្តឹងចាប់ហ៊ុនសែនមកកាត់ទោសឬដកហ៊ុនសែនចេញពីអំណាចបាន ។ ការពិតសត្រូវជាតិខ្មែរក្តី ពួកអាយ៉ងក្តី កំពុងតែសើចចំអកនិងសប្បាយចិត្តណាស់ដែលខ្មែរខ្លះនាំគ្នាយកកម្លាំងតស៊ូទៅចោល ទៅវាយខុយសទិសដៅ ពុលជឿការឃោសនាបោកប្រាស់អកុសលបែបនេះ ។ ពួកនោះមិនខ្វល់អ្វីទាំងអស់ គេមានតែជួលមនុស្សមកធ្វើបំពុលបន្ថែម ។ បុស្បា អង្គរ